**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ:** ០១ **អយក** សារាចរ

សារាចរណែនាំ

ស្តីពី

ការប្រឡងបញ្ចប់ភូមិសិក្សាផ្នែកចំណេះទូទៅ បំពេញវិជ្ជាសាធារណៈ និងឯកជន

យោង :- ប្រកាសលេខ ២១១ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២៧ មករា ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ

- ប្រកាសលេខ ៧៨ អយក.ប្រក របស់ក្រសួងអប់រំ យុវជន និងកីឡាចុះថ្ងៃទី ២២ មករា ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ
- សេចក្តីណែនាំលេខ ៣៣៨១ អយក.មចទ ចុះថ្ងៃទី ២២ វិច្ឆិកា ២០០៤ ស្តីពីការរៀបចំប្រឡងនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅសំរាប់ឆ្នាំសិក្សា ២០០៤_២០០៥

នៅឆ្នាំសិក្សា ២០០៤_២០០៥នេះ ពិន្ទុសរុបនៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនៅតែរក្សាយកពិន្ទុប្រចាំឆ្នាំ បូកនឹងពិន្ទុប្រឡងថ្នាក់ជាតិ ។ ដោយឡែកការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវយកពិន្ទុប្រចាំឆ្នាំកំនែតំរូវ បូកនឹងពិន្ទុប្រឡងថ្នាក់ជាតិ ។

ដើម្បីអោយការប្រឡងថ្នាក់ជាតិ និងការរៀបចំប្រឡងឆមាសទី១ និងទី២តាមសាលារៀន មានលក្ខណៈល្អប្រសើរ ក្រសួងសូមធ្វើការណែនាំដូចតទៅ :

**I. កាលបរិច្ឆេទប្រឡង :**

**I.1. ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ :**

- កាលបរិច្ឆេទ : ថ្ងៃទី ១១ កក្កដា ២០០៥
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡង : ថ្ងៃទី ១៧ កុម្ភៈ ២០០៥ ដល់ថ្ងៃទី ១៥ មីនា ២០០៥។

**I.2. ប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ :**

- កាលបរិច្ឆេទ : ថ្ងៃទី ០៨ សីហា ២០០៥
- កាលបរិច្ឆេទនៃការទទួលពាក្យសុំប្រឡង : ថ្ងៃទី ១៧ កុម្ភៈ ២០០៥ ដល់ថ្ងៃទី ១៥ មីនា ២០០៥

**II. បេក្ខភាពសិស្ស និងសំណុំលិខិតដាក់ពាក្យប្រឡង :**

**II.1.** សំណុំលិខិតដាក់ពាក្យសុំប្រឡងរបស់បេក្ខជន ត្រូវសរសេរដោយដៃបេក្ខជនផ្ទាល់ (គំរូជូនភ្ជាប់) បិទតែម ៣០០រៀល និងមានភ្ជាប់បង្កាន់ដៃបង់សិទ្ធិសុំប្រឡងដូចខាងក្រោម :

- បេក្ខជនប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ បង់ថ្លៃសិទ្ធិប្រលង ១០០០រៀល ។
- បេក្ខជនប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ បង់ថ្លៃសិទ្ធិប្រលង ១៥០០រៀល ។

II.2. បេក្ខភាព :

ក. បេក្ខភាពប្រឡងសញ្ញាបត្រ មធ្យមសិក្សាបឋមភូមិ :

* សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ÷
  - ដែលមានអាយុ១៤ឆ្នាំយ៉ាងតិច។
  - បានរៀនចប់មធ្យមសិក្សាបឋមភូមិ គ្រប់កំរិតថ្នាក់។
  - បានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី៩។
  - បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា។
  - បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំ ចាប់ពីមធ្យមឡើងទៅ។

  អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

ខ. បេក្ខភាពប្រឡងសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ :

* សិស្សសាលារៀនចំណេះទូទៅសាធារណៈ និងឯកជន ÷
  - មានសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។
  - បានរៀននៅមធ្យមសិក្សាទុតិយភូមិគ្រប់កំរិតថ្នាក់។
  - បានរៀនចប់កម្មវិធីថ្នាក់ទី១២ ។
  - បានគោរពត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុង សំរាប់គ្រឹះស្ថានមធ្យមសិក្សា។
  - បានត្រូវវាយតំលៃផ្នែកសីលធម៌ប្រចាំឆ្នាំចាប់ពីមធ្យមឡើងទៅ។

  អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមគ្រឹះស្ថានសិក្សារបស់ខ្លួនបាន។

  + **លើកលែងតែ :**
  - សិស្សដែលឈប់ដោយមានច្បាប់ ចាប់ពី៤៥ដងឡើងទៅ។
  - សិស្សដែលឈប់ឥតច្បាប់ និងមានច្បាប់ ចាប់ពី៣០ដងឡើងទៅ។
  - សិស្សដែលឈប់ឥតច្បាប់ ចាប់ពី២០ដងឡើងទៅ។
  - សិស្សដែលគ្មានមធ្យមភាគពិន្ទុឆមាសទី១ រឺឆមាសទី២។

* អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រឡងពីមុន រឺអាចដាក់ពាក្យសុំប្រឡង នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងផ្សេងទៀត ដោយគ្រាន់តែធ្វើសេចក្ដីបញ្ជាក់ពីការប្រឡងធ្លាក់លើពាក្យសុំប្រឡង ពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានប្រឡងធ្លាក់ពីមុន។
* អតីតបេក្ខជនដែលបានប្រឡងធ្លាក់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ អាចដាក់ពាក្យសុំប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅតាមមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រឡងពីមុន រឺនៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នៃក្រសួងអប់រំ យុវជន និងកីឡា។

** **កំនត់សំគាល់ :**

* ចំនួនអវត្តមានត្រូវគិតចាប់ពីបវេសនកាល រហូតដល់ថ្ងៃទី **២៣ មិថុនា ២០០៥** សំរាប់សិស្សថ្នាក់ទី ១២ និងថ្ងៃទី **០៤ មិថុនា ២០០៥** សំរាប់សិស្សថ្នាក់ទី ៩។

**II.2. បញ្ជីបេក្ខភាព-បញ្ជីរាយនាមសិស្ស ប្រឡងឆមាសលើកទី១-ទី២ និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ :**

នៅដើមឆ្នាំសិក្សា នាយកវិទ្យាល័យត្រូវផ្ញើបញ្ជីសិស្សថ្នាក់ទី១២ ទៅមន្ទីរអប់រំយុវជន និងកីឡា។ មន្ទីរអប់រំ

យុវជន និងកីឡា ត្រូវវាយបញ្ចូលឈ្មោះសិស្សថ្នាក់ទី១២ដែលទទួលបានពីវិទ្យាល័យនីមួយៗទៅក្នុងកុំព្យូទ័រ។ ក្រោយពីពិនិត្យផ្ទៀងផ្ទាត់ និងកែតម្រូវរួចមន្ទីរត្រូវ ÷

-បោះពុម្ពជាលើកទី១ នូវបញ្ជីរាយនាមសិស្សតាមលំដាប់អក្ខរក្រម តាមបន្ទប់ និងតារាងស្រង់ពិន្ទុប្រឡងឆមាសទី១ តាមបន្ទប់ (ចំនួនបេក្ខជនក្នុងមួយបន្ទប់ត្រូវយកតាមការកំនត់របស់វិទ្យាល័យនីមួយៗ) បញ្ជូនទៅវិទ្យាល័យនីមួយៗយ៉ាងហោចណាស់២សប្តាហ៍មុនថ្ងៃប្រឡងឆមាស។ វិទ្យាល័យនីមួយៗ ក្រោយពីទទួលបានបញ្ជីរាយនាមសិស្សថ្នាក់ទី១២តាមបន្ទប់ ត្រូវថតចំឡងបិទផ្សាយបញ្ជីទាំងនោះអោយសិស្សមើល ដើម្បីពិនិត្យ ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ក្រែងមានការខុសឆ្គង។ ក្រោយពីទទួលពត៌មានត្រឡប់មកវិញ នាយកត្រូវធ្វើបញ្ជីកែតម្រូវ (តាមគំរូលេខ ០១ជូនភ្ជាប់) ទៅមន្ទីរអប់រំ យុវជន និងកីឡាវិញ។

-ក្រោយពីបានទទួលបញ្ជីកែតម្រូវពីវិទ្យាល័យ មន្ទីរអប់រំ យុវជន និងកីឡា ត្រូវកែតម្រូវទិន្នន័យក្នុងកុំព្យូទ័រ រួចបោះពុម្ពផ្ញើទៅសាលាវិញ។

<u>សំគាល់</u> : ក្រដាស ទឹកខ្មៅ សំរាប់បោះពុម្ពបញ្ជីឈ្មោះ និងតារាងស្រង់ពិន្ទុ...ជាបន្ទុករបស់សាលា ដោយប្រើប្រាស់ថវិកា PAP3 ក្នុងខ្ទង់សម្ភារៈមូលដ្ឋាន។

-បោះពុម្ពជាលើកទី២នូវបញ្ជីបេក្ខភាព តារាងស្រង់ពន្ទុប្រចាំឆ្នាំ ផ្ញើទៅវិទ្យាល័យនីមួយៗក្រោយពេលប្រឡងឆមាសលើកទី១ពីរសប្តាហ៍ ដើម្បីអោយវិទ្យាល័យនីមួយៗ ធ្វើការផ្ទៀងផ្ទាត់។ ក្នុងការផ្ទៀងផ្ទាត់នោះ វិទ្យាល័យនីមួយៗត្រូវយកវិញ្ញាបនប័ត្របណ្តោះអាសន្នមធ្យមសិក្សាបឋមភូមិធ្វើជាគោល ផ្ទៀងផ្ទាត់ជាមួយសលាកប័ត្រឯកត្តជន និងបញ្ជីបេក្ខភាព។ បើពិនិត្យទៅមានខុសឆ្គង វិទ្យាល័យនីមួយៗ ត្រូវកែដោយប៊ិចក្រហមនៅលើបញ្ជីបេក្ខភាព និងតារាងស្រង់ពិន្ទុប្រចាំឆ្នាំ ព្រមទាំងធ្វើបញ្ជីរាយនាមឈ្មោះសិស្ស ដែលត្រូវកែតម្រូវ (តាមគំរូលេខ០២ជូនភ្ជាប់) ផ្ញើមកការិយាល័យប្រឡង នៃនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដោយភ្ជាប់មកជាមួយនូវពាក្យសុំប្រឡងរបស់បេក្ខជនផង អោយបានមុនថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥។

* លោកនាយក-នាយិកាសាលា :

- ត្រូវពិនិត្យសំនុំលិខិតដាក់ពាក្យសុំប្រឡងរបស់សិស្ស ដោយផ្ទៀងផ្ទាត់អោយបានត្រឹមត្រូវនូវ ឈ្មោះថ្ងៃ ខែ ឆ្នាំកំនើត ទីកន្លែងកំនើត ឈ្មោះឪពុកម្តាយរបស់សិស្ស ដែលសរសេរក្នុងពាក្យសុំប្រឡង និងសលាកប័ត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ។ ពាក្យសុំប្រឡង និងសលាកប័ត្រឯកត្តជនរបស់សិស្ស ត្រូវសរសេរអោយច្បាស់។ ត្រូវណែនាំសិស្សអោយរក្សាទុកហ្វីល្មរូបថត ដែលបានបិទលើសលាកប័ត្រឯកត្តជន ដើម្បីងាយស្រួលក្នុងការសុំធ្វើវិញ្ញាបនប័ត្របណ្តោះអាសន្ន នៅពេលប្រឡងជាប់។
- ត្រូវណែនាំអោយសិស្សសរសេរសំនុំលិខិតដាក់ពាក្យសុំប្រលងដោយខ្លួនឯង ចៀសវាងប្រមូលយកទៅអោយគ្រូទទួលបន្ទុកថ្នាក់ វិមិត្តកត្តិ រឺអ្នកដទៃសរសេរជំនួស។
- ត្រូវចុះហត្ថលេខា និងបោះត្រាលើសលាកប័ត្រពិន្ទុប្រចាំឆ្នាំ របស់សិស្សថ្នាក់ទី៩ (បេក្ខជនម្នាក់ៗបំពេញជា ២ច្បាប់) ដែលសរសេរបំពេញដោយផ្ទាល់ដៃសិស្ស ចៀសវាងការកោសលុប រឺសរសេរត្រួត។ ចំពោះសិស្សថ្នាក់ទី១២ ពុំមានសលាកប័ត្រពិន្ទុប្រចាំឆ្នាំទេ។ បន្ទាប់ពីឈប់ទទួលពាក្យសុំប្រឡង ត្រូវរាប់ចំនួនសិស្សដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ និងចំនួនសិស្សដាក់ពាក្យសុំប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ផ្ញើមកមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុងដោយ ÷

• ១ច្បាប់សំរាប់មន្ទីរអប់រំ យុវជន និងកីឡា ដើម្បីវាយឈ្មោះសិស្សបញ្ចូល Diskette តាមវិទ្យាល័យនីមួយៗ រួចមន្ទីរអប់រំយុវជន និងកីឡាខេត្ត-ក្រុងផ្ញើ Diskette នោះ មកនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

អោយបានមុនថ្ងៃទី ០១ មេសា ២០០៥។

១ច្បាប់ សំរាប់ក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ) ដោយភ្ជាប់វិញ្ញាបនប័ត្របណ្ដោះអាសន្ន មធ្យមសិក្សាបឋមភូមិ សម័យប្រឡងត្រឹមឆ្នាំ ២០០២ រឺមុនឆ្នាំ ២០០២ អោយបានមុនថ្ងៃទី ០១ មេសា ២០០៥ ដើម្បីក្រសួងផ្ទៀងផ្ទាត់បេក្ខភាព។

**III. ការកំនត់មណ្ឌលប្រឡង :**

កន្លងមក គ្រឹះស្ថានសិក្សាមួយចំនួននៅតាមខេត្ត_ក្រុងដែលត្រូវបានយកធ្វើជាមណ្ឌលប្រឡង នាយក_នាយិកាសាលាពុំទាន់បានរៀបចំអោយអស់លទ្ធភាព ដើម្បីធានាអោយដំណើរការប្រលងប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយ។ ដូចនេះ លោក_លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា ត្រូវជ្រើសរើសយកគ្រឹះស្ថានណា ដែលមានដំបូលពុំធ្លុះធ្លាយ មានរបងព័ទ្ធជុំវិញ មានមាត់ច្រកចេញ ចូល មានសោរចាក់ត្រឹមត្រូវ សំរាប់ធ្វើជាមណ្ឌលប្រឡង និងណែនាំអោយ នាយក_នាយិកាសាលា ដែលសាលារបស់ខ្លួនត្រូវបានជ្រើសរើសធ្វើជាមណ្ឌលប្រឡង សំអាតទីធ្លា អគារ បន្ទប់អនាម័យអោយហើយស្រេចមុនដំនើរការប្រឡង។ បន្ទប់ប្រឡងនីមួយៗ ត្រូវរៀបចំអោយមាន តុ ជើងម៉ាមាំទាំ ដើម្បីអោយបេក្ខជនងាយស្រួលក្នុងការសរសេរកិច្ចការ។ បើតុ ជើងម៉ាពុំមាំទាំ ត្រូវជួសជុល រឺរកជើងម៉ាថ្មីមកប្ដូរ។ បន្ទប់ប្រឡងនីមួយៗ ត្រូវអោយមានតុ២៥យ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាពីរនាក់) និង១៣តុយ៉ាងតិច (តុសំរាប់សិស្សអង្គុយរៀនធម្មតាបួននាក់)។

មណ្ឌលប្រឡងនីមួយៗ ត្រូវមានប្រដាប់បំពងសំឡេង ដែលអាចប្រើប្រាស់បាន នៅពេលដំណើរការប្រឡង។ សាលាដែលត្រូវយកធ្វើមណ្ឌលប្រឡងត្រូវរក្សាទុកបុគ្គលិក ២រឺ៣នាក់ នៅតាមទំហំមណ្ឌលប្រឡង។ បុគ្គលិករក្សាទុកនេះត្រូវជ្រើសរើសអ្នកដែលចេះប្រើប្រាស់ និងរៀបចំប្រដាប់បំពងសំឡេង ហើយឈ្លាសវៃក្នុងការដោះស្រាយកង្វះខាតសំភារៈផ្សេងៗ។ ហាមដាច់ខាត ការលក់ដូរនៅ ក្នុងមណ្ឌលប្រឡង ក្នុងរយៈពេលដំនើរការ ការងារប្រឡង។ ត្រូវផ្ញើកំនត់មណ្ឌលប្រឡង ទៅក្រសួង (នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ) អោយបានមុនថ្ងៃទី ០១ មេសា ២០០៥។

**IV. សំណើប្រធានវិញ្ញាសាប្រឡង :**

លោកគ្រូ អ្នកគ្រូបង្រៀនថ្នាក់ទី១២ និងទី៩ ត្រូវផ្ញើសំនើប្រធានវិញ្ញាសាប្រឡង ១វិញ្ញាសាក្នុងមួយមុខវិជ្ជាសំរាប់អ្នកបង្រៀនម្នាក់ ដោយភ្ជាប់អត្រាកំនែមកជាមួយផង ដើម្បីជាទុនសំរាប់ក្រសួងពិចារណា និងជ្រើសរើស។ លោកគ្រូ អ្នកគ្រូដែលជាអ្នកស្នើប្រធានវិញ្ញាសា ត្រូវរក្សាការសំងាត់ និងគំលៃមុខវិជ្ជារបស់ខ្លួន ដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះមុខក្រសួង ។

ផ្នែកខាងលើនៃសំណើប្រធានវិញ្ញាសានីមួយៗ ត្រូវសរសេរតាមគំរូជូនភ្ជាប់។ សំណើប្រធានវិញ្ញាសានីមួយៗត្រូវដាក់ក្នុងស្រោមសំងាត់ ដោយបញ្ជាក់មុខវិជ្ជាលើស្រោមនោះផង។

នាយក_នាយិកាសាលា ត្រូវប្រមូលស្រោមសំណើប្រធានវិញ្ញាសាទាំងអស់ ដាក់ក្នុងស្រោមសំងាត់រួម រួចផ្ញើទៅនាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ តាមរយៈមន្ទីរអប់រំ យុវជន និងកីឡាខេត្ត_ក្រុងអោយបានមុនថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥។

***ចំពោះវិញ្ញាសាដែលត្រូវធ្វើសំណើមានដូចតទៅ :***

ក. ***<u>សំរាប់ការប្រឡងសញ្ញាប័ត្រមធ្យមសិក្សា ទុតិយភូមិ</u>*** :

១_ ភាសាខ្មែរ .................. រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។

២_ គណិតវិទ្យា ............... រយៈពេល ១៥០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១២៥។

៣_ រូបវិទ្យា ............... រយៈពេល ៩០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៧៥។
៤_ គីមី ............... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
៥_ ជីវវិទ្យា ............... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
៦_ ផែនដីវិទ្យា ............... រយៈពេល ៣០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៥។
៧_ ប្រវត្តិវិទ្យា ............... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣៧។
៨_ ភូមិវិទ្យា ............... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣៨។
៩_ សីលធម៌_ពលរដ្ឋវិជ្ជា ....... រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។
១០_ សំនួរទំរង់បិទ ............ រយៈពេល ៦០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។

**ខ. <u>សំរាប់ការប្រឡងសញ្ញាបត្រមធ្យមសិក្សា បឋមភូមិ</u> :**

១_ ភាសាខ្មែរ ............... រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។
២_ គណិតវិទ្យា ............... រយៈពេល ១២០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ១០០។
៣_ រូបវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០។
៤_ គីមី ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៥_ ជីវវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៦_ ផែនដីវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៧_ ប្រវត្តិវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៨_ ភូមិវិទ្យា ............... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ២៨។
៩_ សីលធម៌_ពលរដ្ឋវិជ្ជា ....... រយៈពេល ៤០នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៣០។
១០_ ភាសាបរទេស ........... រយៈពេល ៤៥នាទី ត្រូវបានពិន្ទុ ពី ០ ដល់ ៥០។

លោក_លោកស្រីប្រធានមន្ទីរអប់រំយុវជន និងកីឡាត្រូវផ្សព្វផ្សាយការណែនាំនេះដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សា ដើម្បីអោយការអនុវត្តមានប្រសិទ្ធភាពខ្ពស់។

<u>**ចំលងជូន**</u> :
-ទីស្តីការគណៈរដ្ឋមន្ត្រី
«ដើម្បីសូមជ្រាបជាពតិមាន»
-គ្រប់សាលាខេត្ត_ក្រុង
«ដើម្បីជូនជ្រាបជាពតិមាន»
-គ្រប់អង្គភាពនៃទីស្តីការក្រសួងអយក
«ដើម្បីជាពតិមាន»
-មន្ទីរអយក គ្រប់ខេត្ត-ក្រុង
«ដើម្បីអនុវត្ត»
- កាលប្បវត្តិ
- ឯកសារ-នា.មចទ

ភ្នំពេញ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០០៥
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

បណ្ឌិត កុល ផេង